ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៤១១ ៤ព.ណ ស៊ីជ

ភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ អ្នកនាំចេញ និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា៖ ដើម្បីបន្តពង្រឹងយន្តការនៃការផ្តល់សេវាសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព និងបន្ថយពេលវេលាឲ្យកាន់តែតិចក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមដល់ផលិតករ និងអ្នកនាំចេញ ក្រសួងពាណិជ្ជកម្ម សម្រេចផ្តល់សិទ្ធិបន្ថែមដល់ថ្នាក់នាយកដ្ឋាននាំចេញ-នាំចូល និងថ្នាក់អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្នុងការពិនិត្យ និងអនុម័តការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ គ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យ ប្រវត្តកម្ម ចាប់ពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៧។

ជាមួយគ្នានេះដែរ ក្រសួងពាណិជ្ជកម្ម នឹងកែសម្រួល និងកាត់បន្ថយដំណាក់កាលនៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ជាបន្តទៀត ដើម្បីសម្រួលពាណិជ្ជកម្ម និងបង្កើតបរិយាកាសធុរៈកិច្ចនៅកម្ពុជា អោយកាន់តែល្អប្រសើរ។

អាស្រ័យហេតុនេះ សូម លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ អ្នកនាំចេញ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សូមអរគុណ!

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ/ ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

# ដំណើរការ

# ការផ្ដល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (CO) តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

